ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
នាយកដ្ឋានព័ត៌មាន និងឯកសារ

# សេចក្តីជូនព័ត៌មាន

ឆ្លើយតបនឹងការអំពាវនាវរបស់អង្គការអន្តរជាតិហ្វ្រង់កូហ្វូនី (OIF) ដល់ប្រទេសជាសមាជិក ឲ្យចូលរួមផ្តល់វិភាគទានដល់ "មូលនិធិសាមគ្គីភាពបន្ទាន់របស់អង្គការអន្តរជាតិហ្វ្រង់កូហ្វូនី" ដើម្បីជួយដល់ប្រទេសហៃទី ដែលទទួលរងគ្រោះការវាយប្រហារដោយព្យុះ Matthew កាលពីថ្ងៃទី ០៤ ខែតុលា ឆ្នាំ២០១៦ និងដើម្បីបង្ហាញនូវសាមគ្គីភាពរបស់ព្រះរាជាណាចក្រកម្ពុជា ដែលជាសមាជិកមួយរបស់អង្គការអន្តរជាតិហ្វ្រង់កូហ្វូនី ជាមួយប្រទេសហៃទី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានសម្រេចចូលរួមផ្តល់វិភាគទានរបស់រាជរដ្ឋាភិបាលកម្ពុជា ចំនួន ៥០.០០០ ដុល្លារអាមេរិក ដល់មូលនិធិខាងលើនេះ។

ភ្នំពេញ, ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៦

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh